UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

ភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩

សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យនៅកម្ពុជា

# "ក្រុម៧៨" ត្រូវបានបណ្តេញចេញ ៈ
# ឱកាសមួយត្រូវបានបាត់បង់ក្នុងការរួមចំណែកអភិវឌ្ឍន៍
# ដំណើរថយក្រោយនៃនីតិរដ្ឋ

នៅថ្ងៃនេះ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានសំដែងការសោកស្តាយចំពោះការបណ្តេញចេញនាពេលថ្មីៗនេះ នៅរាជធានីភ្នំពេញ នូវប្រជាពលរដ្ឋដែលនៅសេសសល់ទាំងប៉ុន្មាននៃសហគមន៍ "ក្រុម៧៨" ។

"យើងខ្ញុំមានការសោកស្តាយជាខ្លាំង ដោយសារប្រជាពលរដ្ឋនៃក្រុម៧៨ ត្រូវបានគេឲ្យចាកចេញពីលំនៅដ្ឋានរបស់ខ្លួន មុនការស្នើសុំសិទ្ធិកម្មសិទ្ធិលើដីធ្លីរបស់គាត់ត្រូវបានសំរេចដោយយន្តការរដ្ឋបាល ឬប្រព័ន្ធយុត្តិធម៌ពាក់ព័ន្ធ ។ ការឲ្យចាកចេញនេះ ជាសញ្ញាមួយប្រាប់ទៅសហគមន៍ដទៃទៀត ដែលមានការស្នើសុំដូចគ្នានេះថា បើទោះជាពួកគេមានសិទ្ធិតាមផ្លូវច្បាប់ហើយក្តី ក៏ផលប្រយោជន៍នៃការអភិវឌ្ឍន៍ យកប្រៀបលើនីតិវិធីត្រឹមត្រូវ និងច្បាប់ភូមិបាលដែរ" ។

"ការឲ្យចាកចេញនេះ ដូចជាការបណ្តេញចេញឯទៀតដែរនៃប្រជាពលរដ្ឋក្រីក្រនៅទីក្រុងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្ហាញផងដែរអំពីអសមត្ថភាពនៃប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដីធ្លី ជាពិសេសកម្មវិធីចេញប័ណ្ណកម្មសិទ្ធិដីធ្លី ក្នុងការអនុវត្តន៍ទាំងស្រុងនូវច្បាប់ភូមិបាល និងការធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លីសំរាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយមិនគិតពីឋានៈសង្គម ទីតាំង ឬ ទ្រព្យសម្បត្តិរបស់ពួកគេឡើយ " ។

ការបណ្តេញចេញដោយបង្ខំ គួរអនុវត្តតែនៅក្នុងករណីលើកលែងមួយចំនួនប៉ុណ្ណោះ និងដោយគោរពទាំងស្រុងនូវសេចក្តីតម្រូវខាងនីតិវិធីត្រឹមត្រូវ ដែលមានចែងក្នុងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ រដ្ឋាភិបាលត្រូវធានាថា បុគ្គលទាំងឡាយដែលត្រូវបានគេឲ្យចាកចេញពីដីធ្លីរបស់ខ្លួន

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

ទទួលបានសំណងសមរម្យ និងឬ ផ្តល់ដីធ្លីសមរម្យមានគុណភាពប្រសើរជាង ឬមានតំលៃស្មើគ្នា និងមានផ្ទះសម្បែងសមរម្យ មុននឹងឲ្យពួកគាត់ចាកចេញ ។ ការចរចាគួរតែមានតម្លាភាព មានការចូលរួម និងមិនគួរធ្វើក្រោមការគាបសង្កត់ ឬការបង្ខិតបង្ខំឡើយ ។

យើងខ្ញុំស្វាគមន៍ថា សាលាក្រុងភ្នំពេញបានធ្វើការចរចាសំណងជាមួយគ្រួសារដែលនៅសេសសល់ រហូតមកទល់ព្រឹកនេះ ហើយនៅទីបញ្ចប់ ការបណ្តេញចេញដោយបង្ខំ និងដោយហឹង្សាលើប្រជាពលរដ្ឋនៃក្រុម៧៨ ត្រូវបញ្ចៀសបាន ។ ទោះជាយ៉ាងណាក៏ដោយ ការឲ្យទៅតាំងលំនៅថ្មីនេះ មិនត្រូវបានធ្វើដោយស្ម័គ្រចិត្តនោះទេ ដោយសារគ្រួសារទាំងនោះបានចាកចេញដោយការបង្ខិតបង្ខំ ហើយបានបង្ហាញពីការគ្មានជំរើសអ្វីផ្សេងពីនេះ ក្រៅតែពីការទទួលយកសំណងដែលមិនធន់ល្មម ។

ការបណ្តេញចេញ និងការតាំងលំនៅថ្មី ជូនកាល ត្រូវបញ្ជាក់ហេតុផលត្រឹមត្រូវតាមផ្លូវច្បាប់និងតាមការចាំបាច់ ដោយរួមទាំងអំពីគោលបំណងនៃការអភិវឌ្ឍន៍ ។ សាលាក្រុងភ្នំពេញបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីអភិវឌ្ឍន៍ទីក្រុង ហើយមានសិទ្ធិគ្រប់បែបយ៉ាងដើម្បីបន្តធ្វើដូច្នេះ ។ ប៉ុន្តែ ការអភិវឌ្ឍន៍នេះ មិនគួរធ្វើឲ្យខាតបង់ប្រយោជន៍របស់អ្នកភូមិឡើយ ។ យើងខ្ញុំជឿជាក់ថា ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវច្បាប់ភូមិបាល គឺជារឿងសមស្រប ក្នុងការធានាថា ការអភិ-វឌ្ឍន៍ទីក្រុងដែលមានបញ្ចូលផលប្រយោជន៍ប្រជាពលរដ្ឋទាំងនោះផងដែរ ។ ការបណ្តេញចេញ និងការតាំងលំនៅថ្មីជាបន្តបន្ទាប់នាពេលថ្មីៗនេះ បានប៉ះពាល់ដល់ប្រជាពលរដ្ឋក្រីក្រនៅទីក្រុង និងបាននាំឲ្យមានការជួយសង្គ្រោះបន្ទាន់ខាងមនុស្សធម៌ ដែលជាការផ្ទុយទៅនឹងគោលដៅរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ។

អនុលោមតាមអនុសាសន៍របស់អ្នកជំនាញការនៃអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានា យើងខ្ញុំសូមជំរុញលើកទឹកចិត្តដល់រដ្ឋាភិបាល មេត្តាគិតគូយ៉ាងហ្មត់ចត់ដល់ការអនុម័តការផ្អាកសិនរាល់ការបណ្តេញចេញនៅកម្ពុជា ដោយរងចាំរហូតដល់មានក្របខ័ណ្ឌច្បាប់មួយច្បាស់លាស់ ត្រូវបានអនុម័តដើម្បីណែនាំអំពីសនិទានភាព និងដំណើរការនៃការបណ្តេញចេញ និងការតាំងលំនៅថ្មី ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សូមបញ្ជាក់ជាថ្មីអំពីការសន្យាធ្វើការជាមួយរដ្ឋាភិបាល និងស្ថាប័នជាដៃគូឯទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់នេះ ដើម្បីគាំទ្រដល់ការស្វែងរក និងការអនុវត្តន៍នៃដំណោះស្រាយតាមផ្លូវច្បាប់ និងដោយយុត្តិធម៌ ។

សារតា :

ប្រជាពលរដ្ឋភាគច្រើនក្នុងក្រុម៧៨ បាននឹងកំពុងរស់នៅក្នុងភូមិ១៤ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៨០ មក ។ ចាប់ពីពេលនោះមក តំលៃដីធ្លីនៅតំបន់នោះឡើងខ្ពស់កប់ពពក បានធ្វើឲ្យតំបន់នោះក្លាយជាទីតាំងដែលទាក់ទាញការវិនិយោគ ។ គ្រួសារជាច្រើនមានសំណុំឯកសារផ្លូវការដែលជាតឹកតាងបញ្ជាក់ថា ពួកគេបានបំពេញតាមលក្ខណៈវិនិច្ឆ័យសំរាប់សិទ្ធិភោគៈ តាមច្បាប់ភូមិបាលឆ្នាំ២០០១ ។ ផ្អែកលើមូលដ្ឋាននោះ ក្នុងឆ្នាំ២០០៤ ប្រជាពលរដ្ឋមួយចំនួនក្នុងក្រុម ៧៨ បានស្នើទៅអាជ្ញាធរសុរិយោដីសុំឲ្យវាយតំលៃពីសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ និងពីការទទួលបានប័ណ្ណកម្មសិទ្ធិលើដីនោះ ។ សំណើររបស់ពួកគាត់មិនមានការឆ្លើយតបទេ បើទោះជាគាត់បានព្យាយាមជារៀងរហូតមក សុំឲ្យមានការដោះស្រាយពីគណៈកម្មការសុរិយោដី សាលាដំបូងក្រុងភ្នំពេញ និងអាជ្ញាធរក្រុងក្ដី ។

ផ្ទុយទៅវិញ អាជ្ញាធរក្រុង និងអាជ្ញាធរមូលដ្ឋាន បានចេញសេចក្ដីជូនដំណឹងពីការបណ្ដេញចេញចំនួនប្រាំមួយលើក ដល់គ្រួសាប្រជាពលរដ្ឋទាំងនោះ ការជូនដំណឹងដំបូងបំផុតគឺក្នុងឆ្នាំ២០០៦ ហើយចុងក្រោយបំផុតគឺក្នុងខែមេសា ឆ្នាំ២០០៩ ។ ការព្យាយាមរបស់សហាគមន៍នេះដើម្បីតវ៉ាអំពីនីត្យានុកូលភាពនៃសេចក្ដីជូនដំណឹងចុងក្រោយនេះ ត្រូវបានច្រានចោលដោយសាលាដំបូងក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍ ដោយមិនបានពិនិត្យពិចារណាឲ្យបានច្បាស់លាស់អំពីបញ្ញត្តិច្បាប់ភូមិបាលឡើយ ។

សាលារាជធានីភ្នំពេញ បានប្រកាសពីចេតនារបស់ខ្លួន ដើម្បីធ្វើការបណ្ដេញចេញនៅថ្ងៃទី១៧ កក្កដា មុនពេលដែលយន្ដការរដ្ឋបាល និងយន្ដការយុត្តិធម៌ទាំងនោះ បានអនុញ្ញាតត្រឹមត្រូវដើម្បីកំណត់អំពីឋានៈគតិយុត្តិ និងសិទ្ធិកម្មសិទ្ធិលើដីធ្លី បានឈានដល់ការសំរេចចុងក្រោយមួយអំពីករណីនេះ ។

នៅថ្ងៃដែលគេគ្រោងធ្វើការបណ្ដេញចេញ មានប្រជាពលរដ្ឋតែប្រាំពីរគ្រួសារប៉ុណ្ណោះនៅលើទីតាំងនោះ ។ ប្រជាពលរដ្ឋ ៦៦ គ្រួសាររស់នៅក្នុងក្រុម ៧៨ នោះ ដែលភាគច្រើន កាលពីដើមខែកក្កដានេះ បានទទួលយកសំណងដែលមិនធន់ល្មម សំរាប់ដីធ្លីរបស់ខ្លួន ដោយចុះញ៉មតាមការគាបសង្កត់ និងការបំភិតបំភ័យរបស់អាជ្ញាធរ ដោយរួមទាំងការប្រាប់ឲ្យដឹងថានៅថ្ងៃទី១៧ ខែកក្កដានឹងមានកំលាំងនគរបាល និងយោធាដល់ទៅ ៧០០ នាក់ ប្រើកំលាំងបណ្ដេញប្រជាពលរដ្ឋទាំងនោះ ។

ទីបំផុត នៅព្រឹកព្រលឹមថ្ងៃទី១៧ ខែកក្កដា មានកំលាំងនគរបាល និងយោធាប្រមាណជា ៧០ នាក់ បានមានវត្តមាន នឹងត្រៀមប្រើកំលាំងបណ្ដេញប្រជាពលរដ្ឋដែលនៅសល់ទាំងប៉ុន្មានចេញពីទីតាំងនោះ ។ សាលារាជធានីបានធ្វើការចរចា នៅនាទីចុងក្រោយ ជាមួយគ្រួសារប្រជាពលរដ្ឋទាំងនោះ តំឡើងប្រាក់សំណងតិចតួចថែមទៀត តែនៅមិនធន់ល្មម ។ ការបណ្ដេញចេញដោយអំពើហឹង្សាត្រូវបញ្ចៀសបាន ។